METHODFINDER



www.MethodFinder.net

# Practitioner's Guide:

## កំណត់ត្រាលំអិតអំពីតំបន់

Deutsche Gesellschaft für Technische Zusammenarbeit (GTZ) GmbH

Bundesministerium für wirtschaftliche Zusammenarbeit und Entwicklung

Ministry of Land Management, Urban Planning and Construction

Copyright: Royal Government of Cambodia – GTZ supported: Land Administration and Management Project (LMAP)

Concept and Layout: Nikolaus Schall / Michael Becker

**បទអត្ថាធិប្បាយសង្ខេប :**



មានប្រភេទខុសគ្នាៗច្រើនពីកំណត់ត្រាលំអិតនៃតំបន់ ដែលភាពខុសៗគ្នា ទៅតាមលក្ខណៈធម្មជាតិរបស់តំបន់និងបុព្វហេតុនានាដែលកំណត់ត្រាលំអិតនេះ ត្រូវបានធ្វើឡើងនោះ ។ ឧទាហរណ៍ នៃកំណត់ត្រាលំអិតពីតំបន់រួមមាន :

- ការសិក្សាអំពីលក្ខណៈប្រជាសាស្ត្រសង្គមរូបវ័ន្តសេដ្ឋកិច្ចនិងបរិស្ថានរបស់តំបន់ណាមួយ ឬ ទីតាំងកំណត់ណាមួយ ( ឧទាហរណ៍ ថ្នាក់ខេត្ត តំបន់ឬរដ្ឋអំណាចមូលដ្ឋាន ) ។ ការសិក្សា នេះអាចកំណត់ពីតំរូវការនានារបស់ប្រជាជនដែល កំពុងរស់នៅក្នុងទីតាំងសិក្សាក៏ដូចជាឱកាសនានាសំរាប់ការអភិវឌ្ឍន៏ទៅអនាគត និងឧបសគ្គ ដែលអាច រាំងដល់ការអភិវឌ្ឍន៏ ។
- ការវិភាគពីក្រុមនៅក្នុងសហគមន៏ដែលមានលក្ខណៈរួម ឧទាហរណ៏ ក្រុមមនុស្សជំទង់ ក្រុមជន ចំណូល ស្រុក ក្រុមប្រជាជនក្រីក្រជាដើម ។
- កំណត់ត្រាលំអិតដែលរៀបចំសំរាប់ ឬដោយថ្នាក់តំបន់ ឬដោយស្ថាប័ន ថ្នាក់មូលដ្ឋានដើម្បីត្រួតពិនិត្យការ អនុវត្តន៏ការងារផ្ទៃក្នុងរបស់ខ្លួន និង ទំនាក់ទំនងរបស់ ខ្លួនជាមួយនឹងសហគមន៏ទូទៅ ។

នៅក្នុងករណីនិមួយៗ កំណត់ត្រាលំអិតពីតំបន់កំណត់ពីស្ថានភាពបច្ចុប្បន្នរបស់ប្រជាជននិងធនធាននានានៅ ក្នុងតំបន់ និងកំណត់ផងដែរនូវទីតាំងនានា ដែលអាចធ្វើការអភិវឌ្ឍន៏បានដើម្បីថែរក្សា ឬកែលំអរគុណភាពនៃជីវភាព រស់នៅសំរាប់ប្រជាជនក្នុងតំបន់នោះ ។ ការកសាងកំណត់ត្រាលំអិតអំពីតំបន់ គឺជាជំហ៊ានដ៏សំខាន់នៅក្នុងការកសាង ផែនការអភិវឌ្ឍន៏តំបន់ ។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

# កំណត់ត្រាលំអិតអំពីតំបន់

## អ្នកដែលអាចប្រើប្រាស់វិធីសាស្ត្រសំខាន់ជាងគេ :



កំនត់ត្រាលំអិតអំពីតំបន់ត្រូវបានប្រើប្រាស់ដោយអ្នករៀបចំកសាងផែនការសហគមន៏អ្នកអភិវឌ្ឍន៍ដីធ្លីនិងអ្នកវិនិយោគមុខជំនួញដើម្បីជួយពួក គេឱ្យយល់ដឹងពីតំបន់ណាមួយឬក៏ដើម្បីធ្វើការសិក្សាស្វែងរកឱកាសសំរាប់ការវិនិយោគនៅក្នុងតំបន់នោះ ។

## គោលបំណងនៃវិធីនេះ



កំណត់ត្រាលំអិតអំពីតំបនគឺជាការចាំបាច់សំរាប់កំណត់នូវតំរូវការចាំបាច់នាពេលអនាគតរបស់ប្រជាជនដែលកំពុងរស់នៅក្នុងតំបន់ក្នុងខេត្តឬសហគមន៏ និង សក្តានុពលរបស់ទីតាំងនោះសំរាប់ការអភិវឌ្ឍន៏ ។ ការផលិតកំណត់ត្រាលំអិតអំពីតំបន់ផ្តល់នូវពតិមានជាមូលដ្ឋានសំខាន់ដែលចាំបាច់សំរាប់ការរៀបចំកសាងផែនការថ្នាក់តំបន់ប្រកបដោយប្រសិទ្ធភាព ។

**កំណត់ត្រាលំអិត អំពីតំបន់គឺជាឧបករណ៏ដ៏សំខាន់នៅក្នុងការកសាងផែនការ :**

- ថ្នាក់តំបន់ និងហេដ្ឋារចនាសម្ព័ន្ធផ្នែករូបវ័ន្តនៅមូលដ្ឋាន ដូចជាផ្លូវ អាគារ ប្រព័ន្ធលូទឹក ។ល។
- ការអភិវឌ្ឍន៏មុខជំនួញ និង ឧស្សាហកម្មថ្នាក់តំបន់ និងមូលដ្ឋាន ។
- សេវាកម្មថ្នាក់តំបន់ និង មូលដ្ឋានដូចជា សាលារៀន មជ្ឈមណ្ឌលសុខភាព មន្ទីរពេទ្យ ។ល។
- ការរៀបចំគ្រប់គ្រងបរិស្ថាន ថ្នាក់តំបន់ និងមូលដ្ឋាន ដូចជាកាកសំណល់ ទីតាំងសំរាប់ឧស្សាហកម្ម ។ល។

ក្រុមការងាររៀបចំកសាងផែនការសំរាប់រដ្ឋាភិបាលថ្នាក់តំបន់ ឬ ក្រុមទីប្រឹក្សានានា ឬ ថ្នាក់តំបន់អាចរៀបចំកសាងកំណត់ត្រាលំអិតពីតំបន់បាន ។ កំណត់ត្រាលំអិតនេះត្រូវ បានរៀបចំកសាងឡើងជាមួយនឹងជំនួយពីគ្រប់ស្ថាប័នរដ្ឋដែល ពាក់ព័ន្ធគណៈកម្មាធិការអភិវឌ្ឍន៏ថ្នាក់តំបន់ ឬទីប្រឹក្សាឯកជន ។ ការចូលរួមការងារពីសហគមន៏មូលដ្ឋានឱ្យបានកាន់តែច្រើននៅក្នុងវិធីសាស្រ្តដ៏សកម្មនៅក្នុងកំណត់ត្រាលំអិត និងជួយប្រជាជននៅក្នុងតំបន់ដើម្បីយល់អំពីលទ្ធផល និង ប្រើប្រាស់នូវរបក រកឃើញ ទាំងអស់ ។



Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

## ផលប្រយោជន៍

ការប្រមូលពតិមានទាមទារសំរាប់កំណត់ត្រាលំអិតអំពីតំបន់ អាចមានផល ប្រយោជន៍ដ៏សំខាន់សំរាប់ស្ថាប័ន ដែលកសាង ឬ ផ្តួចផ្តើមកសាងកំណត់ត្រាលំអិតរបស់សហគមន៍ក្នុងតំបន់ដែលវាអាច :

- ជួយស្ថាប័នឱ្យយល់បានល្អប្រសើរជាងមុន ពីតំបន់ដែលពួកគេកំពុងធ្វើការ ។
- បង្ហាញស្ថាប័នជូនដល់ប្រជាជនដែលកំពុងរស់នៅក្នុងតំបន់ ឬបង្កើនកំណត់ត្រាលំអិត របស់វា និងភាពយល់ដឹង ពីសេវាកម្មរបស់ខ្លួន ។
- កំណត់កត្តានានាបញ្ហាផ្សេងៗ និងតំរូវការទាំងឡាយរបស់ប្រជាជន ឬអតិថិជនដែលកំពុងរស់នៅក្នុងតំបន់ ជំរុញឱ្យប្រសើរឡើងនូវជំនាញនានារបស់ស្ថាប័ន ក្នុងការបំពេញ ការងារជាមួយសហគមន៍នានា ដែលរស់នៅក្នុងតំបន់ ហើយធ្វើឱ្យវាមាន ប្រសិទ្ធិភាពកាន់តែខ្ពស់ក្នុង ការនាំមកនូវការផ្លាស់ប្តូរដែលចង់បាននោះ ។
- កំណត់បុគ្គលឬក្រុមដែលមានឥទ្ធិពលខ្លាំងនៅក្នុងតំបន់ឬសហគមន៍ដែលអាចក្លាយជាដៃគូរដ៏មានសារៈ ប្រយោជន៍ ។
- ចិញ្ចឹមបីបាច់ថែរក្សាកិច្ចសហប្រតិបត្តិការក្នុងចំណោមភ្នាក់ងារ និងក្រុមប្រជាជនផ្សេងៗ (ឬប្រសិនបើរៀបចំ មិនបានល្អ រំលែកពួកគេដាច់ដោយឡែក ដើម្បីប្រកួត ប្រជែង សំរាប់ធនធានតិចតួច ) ។
- ជួយការពារដល់ការខ្ជះខ្ជាយធនធានមនុស្សសំភារៈ និងហិរញ្ញវត្ថុ ដោយជួយធានាឱ្យបានថា សកម្មភាពនានា មានលក្ខណៈ ត្រឹមត្រូវនិងមានប្រសិទ្ធិភាព ។
- ជួយស្ថាប័នកំណត់ភាពខិតខំប្រឹងប្រែងរបស់ខ្លួនឱ្យមានប្រសិទ្ធិភាពនូវក្រុមប្រជាជនក្នុងលក្ខណៈមួយសមស្រប ។
- ចិញ្ចឹមបីបាច់ថែរក្សាការចូលរួមរបស់សហគមន៍បំផុសឱ្យប្រជាជនចូលរួមពីវិស័យនានាឱ្យបានទូលំទូលាយនៃ សហគមន៍ដែលកំពុងធ្វើការដោះស្រាយលើបញ្ហាដូចគ្នានៅក្នុងតំបន់ ។
- ជួយត្រួតពិនិត្យលទ្ធផលនៃកម្មវិធី ឬ សកម្មភាពពិសេសណាមួយ និងជួយស្ថាប័នដើម្បីបញ្ចេញសកម្មភាព កែលំអរ ឬ ការពារ ដែលជាការចាំបាច់ ។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

## កំណត់ត្រាលំអិតអំពីតំបន់

### ដែនកំណត់

៥

- កំណត់ត្រាលំអិតអំពីតំបន់ទាមទារនូវទិន្នន័យពិតប្រាកដ ហើយមិនអាចផ្អែក ទាំងស្រុងទៅលើតែការសន្និដ្ឋាននោះឡើយ ។ ការប្រមូលនូវទិន្នន័យទាំងអស់នេះ គឺជាកិច្ចការដែលមានតំលៃខ្ពស់ និងទាមទាររយៈពេលយូរ ។
- មានទិន្នន័យប្រកបដោយសុក្រិតភាពអាចបន្ថយតំលៃ និងការប្រើប្រាស់កំណត់ ត្រាលំអិតអំពីតំបន់បានច្រើន ។
- កំណត់ត្រាលំអិតអំពីតំបន់ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយទាមទារឱ្យប្រមូលទិន្នន័យច្រើន ក៏ប៉ុន្តែទិន្នន័យ ទាំងនោះ អាចប្រមូលយកបានតាមបែបបទដែលអាចកាត់បន្ថយតំលៃបាន ។
- ការថែរក្សាលទ្ធភាពនិងការបង្ហាញពីកំណត់ត្រាលំអិតអំពីតំបន់ ទាមទារនូវជំនាញនៃការបង្ហាញមួយប្រកប ដោយប្រសិទ្ធភាពដើម្បីជៀសវាងបានការបង្ហាញនូវពតិមាន និងទិន្នន័យច្រើនហួសពីតំរូវការ ។
- ប្រសិនបើទិន្នន័យមិនត្រូវបានដាក់ឱ្យមានការប្រើប្រាស់ទូលំទូលាយទេនោះ ផលប្រយោជន៍របស់កំណត់ត្រា លំអិតអំពីតំបន់ អាចនឹងមានកំរិតតូច គឺសំរាប់ តែចំពោះ ក្រុម អ្នករៀបចំកសាង ផែនការតែប៉ុណ្ណោះ ។
- ទាមទារឱ្យមានការធ្វើជំរឿន និងថែរក្សាសុក្រិតភាពរបស់ទិន្នន័យជាប្រចាំ បើសិនចង់ឱ្យកំណត់ត្រាលំអិតអំពី តំបន់មានលក្ខណៈទាន់សម័យ ។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

## គោលការណ៍និងដំណើរការទូទៅ



វាជាការងាយស្រួលនាំដល់ការមានការងារត្រូវបំពេញច្រើនលើសលុប ដោយកិច្ចការ អនុវត្តន៏កំណត់ត្រាលំអិត អំពីតំបន់ ។ទំហំពតិមាន ដែលមានអាច មានទំហំធំធេង ដែលវាអាចជា ការងាយស្រួលធ្លាក់ទៅក្នុងអន្ទាក់នៃការប្រមូលយកពតិមាន ដែលទោះបី ជាមានសារៈប្រយោជន៏ក៏ដោយ ក៏ប៉ុន្តែមិនមាន តំលៃ សំរាប់កិច្ចការកសាងកំណត់ត្រាលំអិត អំពីតំបន់ ។

ដើម្បីចៀសវាង បាននូវរណ្តៅទាំងអស់នេះទាមទារឱ្យមាននូវការសួរដូចខាងក្រោម :

**ហេតុអ្វីបានជាយើងកសាងកំណត់ត្រាលំអិតអំពីតំបន់?**

តើកំណត់ត្រាដែលបានកសាងឡើងសំរាប់កត្តា ឬ តំបន់ណាមួយនោះផ្អែកទៅលើស្ថាប័នអ្វី? តើអ្វីខ្លះដែលទាមទារឱ្យយើងត្រូវដឹង? តើកំណត់ត្រាទូទៅចំនួន២ឬ៣សន្លឹក ដែលទាមទារសំរាប់ជូនអ្នកដែលនៅក្រៅតំបន់ ឬកំណត់ត្រានៃការវិភាគ លំអិតអំពីតំបន់ជា ការចាំបាច់ត្រូវធ្វើឬទេ?ជាការប្រសើរយើងគួតែយល់ឱ្យបានច្បាស់ថាតើហេតុអ្វីបានជាយើងត្រូវការពតិមានទាំងនេះ ?តើអ្នកណាខ្លះនឹង ប្រើ ប្រាស់ទិន្នន័យនេះ និងនៅពេលណា?

**តើអ្វីខ្លះដែលយើងបានដឹងរួចហើយ?**

កំណត់ថាតើពតិមានអ្វីខ្លះ ដែលមានដើម្បីកំណត់ពីចន្លោះ ប្រហោងដែលនាំឱ្យយើងយល់ដឹងអំពីតំបន់ ។ មានទិន្ន ន័យជាច្រើនបែបអាចមាន រួចទៅហើយ ដែលអាចផ្តល់នូវចំលើយនានាចំពោះកត្តាផ្សេងៗដែលចាំបាច់ត្រូវតែលើកយក

មកបង្ហាញនោះ ។

**តើធនធានអ្វីខ្លះដែលយើងមាន?**

តើយើងត្រូវបញ្ចប់ការងារកសាងកំណត់ត្រាលំអិតអំពីតំបន់ក្នុងរយៈពេលប៉ុណ្ណា ? ហើយតើអ្នកណាខ្លះអាចជួយ យើងបាន? តើការងារនេះអាចអស់តំលៃប៉ុន្មាន ? ហើយតើអ្នកណាខ្លះនឹងទទួលខុសត្រូវលើចំណាយទាំអស់នេះ? ពីព្រោះការប្រមូលពតិមាន ទាមទារទាំងពេលវេលា និងថវិការ ។ ការចំណាយ ក៏ត្រូវធ្វើទៅលើការថតចេញនូវកំណត់ ត្រាលំអិត និងការចែកចាយជូនដល់ភាគីពាក់ព័ន្ធទាំងអស់ ។ នៅក្នុងការប្រមូលពតិមាន សំរាប់កំណត់ត្រាលំអិតអំពី តំបន់ជារឿយៗវាជាគំនិតល្អក្នុង ការរៀបចំផែនការជា ប្រចាំសំរាប់ការប្រមូលទិន្នន័យ ។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

## គោលការណ៍និងដំណើរការទូទៅ



-**ប្រមូលទិន្នន័យដែលត្រូវបានគេប្រមូលរួចហើយ** (Harddata)ជាមុន ទើបប្រមូលទិន្នន័យដែល មិនទាន់មានគេប្រមូល (Soft data )ជាក្រោយ ។(Harddata) ទិន្នន័យរឹងគឺជាទិន្នន័យ ឬ រូបភាពដែលអ្នកដ៏ទៃបានប្រមូលទុកពីមុនរួចមកហើយ។ វាជាការ អាចធ្វើទៅបានដែលចំលើយនានាចំពោះសំនួរមួយចំនួនអាចឆ្លើយរួច ហើយដែល កាត់បន្ថយបាននូវតំរូវការ អនុវត្តន៏នូវការ អង្កេតការសាកសួរ ថ្មីទៀត ។ការ ប្រមូលពតិមាន ទាំងនេះជាមុនអាចផ្តល់នូវគំនិតនានាសំរាប់សំនួរមួយ ចំនួនដែលអាចផ្ទៀងផ្ទាត់ជាមួយនឹងទិន្នន័យ (Soft Data)ដែលជាប្រភេទទិន្នន័យស្តីអំពីចំណាប់អារម្មណ៏ ឬ ការអង្កេត នានារបស់ប្រជាជនដែលអាចទាក់ទងបាននៅពេលក្រោយ ។

-**ការបង្ហាញអំពីលទ្ធផល:** គឺការយកចិត្តទុកដាក់ជា សំខាន់នៅក្នុងការបំពេញកិច្ចការកំណត់ត្រាលំអិត អំពីតំបន់ គួរតែជាវិធីដែលអ្នករៀបចំកសាងផែនការ គិតគូរដល់លទ្ធផលនានាចំពោះប្រជាជន ភាគីពាក់ព័ន្ធ និងស្ថាប័នផ្សេងៗ។ វាជាការសំខាន់ក្នុងការកសាងឯកសារដែលជាឯកសារសំខាន់ហើយដែលមានរួចមកហើយចំពោះប្រជាជនដែលពាក់ព័ន្ធផ្ទាល់។ កំណត់ត្រាលំអិតត្រូវតែបង្ហាញនៅក្នុងវិធីសាស្ត្រមួយដែលមានលក្ខណៈងាយស្រួលសំរាប់អនុវត្តន៏ហើយក៏ត្រូវ មានលក្ខណៈច្បាស់លាស់និងគ្រប់ជ្រុងជ្រោយ ។ ប្រសិនបើ នរបាយការណ៏មានទាំងទិន្នន័យនិងរបកគំហើញនៃការអង្កេតវាអាចមានសារៈប្រយោជន៏ដើម្បីកសាងនូវសេចក្តីសង្ខេប អំពីការចែកចាយជាសាធារណៈ ។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

## គោលការណ៍និងដំណើរការទូទៅ



-កំណត់ត្រាលំអិតអំពីតំបន់មានពត៌មាននៅក្នុងករណីខាងក្រោម :

### ១~ ទិដ្ឋភាពទូទៅ :

តើអ្វីខ្លះជាលក្ខណៈរបស់តំបន់? តើព្រំប្រទល់របស់វាមានលក្ខណៈអ្វីខ្លះ? តើកំណត់ត្រាពេលវេលានៃកំណត់ត្រា លំអិតយ៉ាងដូចម្តេច? ភារកិច្ចបឋមនៃការកសាងកំណត់ ត្រាលំអិតអំពីតំបន់ គឺការអនុវត្តន៏នូវទិដ្ឋភាពទូទៅរបស់តំបន់ ។ករណីនេះជួយផ្តល់នូវបរិបទដែលក្នុងនោះផ្តល់ នូវពតិមានលំអិតកាន់តែច្រើនអំពីតំបន់ដែលត្រូវប្រមូលនៅពេលក្រោយនៃការសិក្សានោះ ។ ទិដ្ឋភាពនេះអាចឆ្លុះបញ្ចាំងថាជាការកសាងនូវទិដ្ឋភាពនៃការសិក្សាហើយទិដ្ឋភាពទូទៅគួរតែមានបទអត្ថាធិប្បាយសង្ខេបអំពីតំបន់ :

- ប្រវត្តិសាស្ត្រ
- ទីតាំងភូមិសាស្ត្រ
- ប្រពៃណីទំនៀមទំលាប់
- បណ្តាញថ្នាក់តំបន់ និង ថ្នាក់សហគមន៏
- ទំនាក់ទំនងផ្នែកដឹកជញ្ជូន និង គមនាគមន៏សំខាន់ ៗ
- ទិដ្ឋភាពគន្លឹះ
- សារៈសំខាន់ចំពោះ តំបន់រដ្ឋ និង ជាតិ
- ភាពស្រដៀងគ្នា និង ភាពខុសគ្នាជាមួយតំបន់ជិតខាង សំភារៈទាំងអស់នេះអាចកើតមានរួចហើយនៅក្នុងវិស័យផ្សេងៗដូចជា គោលការណែនាំអំពីរដ្ឋាភិបាល ដល់ថ្នាក់មូលដ្ឋាន សៀវភៅកំណត់ហេតុរបស់សហគមន៏ កំណត់ត្រាក្រុមប្រឹក្សា កំណត់ត្រាលំអិតអំពីតំបន់ខិត្តប័ណ្ណផ្សព្វ ផ្សាយផ្នែកទេសចរណ៏ ។ល ។ទិដ្ឋភាពទូទៅមិនចាំបាច់មានពតិមានលំអិតទេក៏ប៉ុន្តែវាគួរផ្តល់នូវទស្សនៈវិស័យទៅលើលក្ខណៈពិសេសរបស់តំបន់ ។ តួនាទីរបស់ខ្លួននៅក្នុងស្ថានភាពរបស់ជាតិ និងរូបភាពទូទៅនៃស្ថានភាពបច្ចុប្បន្នរបស់ខ្លួន ពាក់ព័ន្ធទៅនឹងការអភិវឌ្ឍន៏ ដែលមានស្ថេរភាព ការរីកលូតលាស់ ឬ ការធ្លាក់ចុះ ។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

## គោលការណ៍និងដំណើរការទូទៅ



តើអ្វីទៅជាលក្ខណៈធម្មជាតិរបស់បរិស្ថានមូលដ្ឋាន ? តើវាមានលក្ខណៈស្ថិតស្ថេរ ឬ ប្រែប្រួល ? តើសកម្មភាពអ្វីខ្លះដែល វាអនុញ្ញាត ឬ ហាមឃាត់ ? ពិនិត្យលើលក្ខណៈ ធម្មជាតិផ្នែករូបវ័ន្ត របស់បរិស្ថាន ដែលក្នុងនោះប្រជាជននៅក្នុងតំបន់រស់នៅ និងប្រកបរបរចិញ្ចឹមជីវិត ។តើសកម្មភាព អ្វីខ្លះដែលវាអនុញ្ញាតឬហាមឃាត់?តើការប្រែប្រួលរបស់បរិស្ថានកើតមានក្នុងលក្ខណៈ ដែល ធ្វើឱ្យសកម្មភាពមួយចំនួនដែលអាចអនុវត្តន៏បានឬមិនបាន? តើយើងអាច ធ្វើអ្វី ខ្លះបាន ដើម្បីសំរបសំរួលឬប្រែប្រួលនូវទំនោរនេះ?តើការប្រែប្រួលទាំងនេះ មានឥទ្ធិពល សំរាប់ ប្រព័ន្ធឬសាធារណៈនានានៅក្នុងតំបន់? តំបន់នេះបង្កើតជាមូលដ្ឋាន ដែលពិនិត្យមើល អំពីឱកាសនានាដែលមានឬគ្មាននៅក្នុងតំបន់ដែលករណីនេះអាចរួមមាន( ប្រសិនបើមាន ការពាក់ព័ន្ធសំរាប់តំបន់ ) :

ធនធានផ្នែករូបវ័ន្តសំរាប់ កសិកម្ម ឈើ នេសាទ និង អាជីវកម្មរ៉ែ

- ▶ លទ្ធភាព និង ភាពសមស្របរបស់ដីធ្លី
- ▶ លក្ខខណ្ឌ និង ឃ្លាំងទ្រព្យសម្បត្តិ បរិស្ថាន និង សហគមន៏
- ▶ ការរៀបចំគ្រប់គ្រង កាកសំណល់សំរាម
- ▶ ការធ្លាក់ចុះនៃគុណភាពដី
- ▶ ការចេញជាជាតិអំបិលរបស់ដី
- ▶ ការប្រើប្រាស់ថ្នាំពុល សត្វល្អិត និង គីមី
- ▶ ការកាប់ព្រៃឈើ
- ▶ ការរៀបចំគ្រប់គ្រងតំបន់ឆ្នេរ
- ▶ ការចេញជាជាតិអំបិលរបស់ទន្លេ ព្រែក និង អូ ។ល។
- ▶ ធនធានធម្មជាតិ ជាផ្កាថ្ម ឬ រុក្ខជាតិក្រោមទឹក

ដែលមានលក្ខណៈពិសេសការស៊ើបអង្កេតគួរតែសំរេចនូវបញ្ហានិង ឧបស័គ្គនានា ដែលប្រឈម មុខ របស់តំបន់ក៏ដូចជាឱកាសនានាដើម្បីសង្កត់ធ្ងន់លើបញ្ហាទាំងអស់នេះជាលក្ខណៈ តំបន់ ឬ មូលដ្ឋាន ។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

គោលការណ៍និងដំណើរការនានា



### ៣- លក្ខណៈប្រជាសាស្រ្ត ៖

តើមានក្រុមអាយុភេទនិងជនជាតិអ្វីខ្លះដែលបានរកឃើញនៅក្នុងសហគមន៍? តើអ្វីទៅជាការប្រែប្រួលផ្នែកប្រជាសាស្រ្ត ?ភារៈកិច្ចទី២ក្នុងការកសាងកំណត់ត្រាលំអិតគឺការកំណត់នូវទំហំ និង លក្ខណៈនានារបស់ប្រជាជនដែលរស់នៅ ។ ទស្សនវិស័យសំខាន់ៗ សំរាប់ពតិមានដែលអាចប្រមូលបានរួមមាន ៖

- ទំនោររបស់ប្រជាជនៈបច្ចុប្បន្នអតីតកាលនិងអនាគតនៃទំហំប្រជាជន ដែលបាន គណនាពីអាត្រាកំណើន និងមូលហេតុនានាសំរាប់រាល់ទំនោរដែលអាចកើតមានឡើង ។
- ទំរង់អាយុ និង ភេទ ៖ មានចំនួនផ្សេងៗគ្នានៅក្នុងក្រុមអាយុ ឧទាហរណ៍ ពីអាយុ 0 ដល់ ៤ឆ្នាំ ពី៥ឆ្នាំដល់៩ឆ្នាំ ។ល ។ដែលមានការប្រែប្រួលទៅតាមពេលវេលាដើម្បីតាមដាន អំពីទំនោរប្រែប្រួល នានា ឧទាហរណ៍ អាយុរបស់ប្រជាជនការគណនាអំពីកំរិតមធ្យមនៃអាយុ អាត្រាភេទ អាត្រា នៅ ក្នុងបន្ទុក គ្រួសារ ។
- ជនជាតិ ៖ ទីកន្លែងកំណើត អាយុ ភេទ មុខងារ និង ភាសា និង ជំនឿសាសនា
- ការផ្លាស់ប្តូរទីលំនៅៈ ការផ្លាស់ប្តូរទីលំនៅចូល និងចេញពីតំបន់ និង សហគមន៍មូលដ្ឋាន រួមទាំងទីកន្លែង កំណើត និង ទីកន្លែងជាគោលដៅ ។
- ទំរង់គ្រួសារ ៖ ភាពខុសគ្នានៃប្រភេទគ្រួសារ ឧទាហរណ៍ គួសារដែលមានអាណាព្យាបាលតែម្នាក់ ទំហំគ្រួសារ គ្រួសារមានមនុស្សតែម្នាក់ ។ល ។
- ការសិក្សាអប់រំ ៖ សមត្ថភាពផ្នែកចំណេះវិជ្ជា សិស្សសាលាពេញម៉ោង ។ល ។
- ប្រាក់ចំណូលៈ ការគណនាអំពីប្រាក់ចំណូលជាមធ្យមភាគរបស់ បុគ្គល គ្រួសារធំ ឬ របស់គ្រួសារតែមួយៗ និងភាពអាចក្លាយជាអ្នកក្រីក្រ ។
- ច្បាប់និងបទបញ្ញត្តិ ៖ប្រភេទ និងស្ថានភាពនៃការរំលោភផ្នែកបទឧក្រិដ្ឋនានា អាយុ និងភេទរបស់ឧក្រិដ្ឋជន ។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

## គោលការណ៍និងដំណើរការទូទៅ



### ៤- ទីផ្សារកំលាំងពលកម្ម :

តើមានពត៌មានស្ដីអំពីតួនាទីនិងការងារអ្វីខ្លះ?តើករណីទាំងនេះមានការប្រែប្រួលឬទេ?តើប្រែប្រួល ក្នុងទំរង់ បែបណាហើយកើតមានជាមួយនិងប្រសិទ្ធិភាពបែបណាខ្លះ ?

ការស៊ើបអង្កេតអំពីផ្សារពលកម្ម ជាទូទៅធ្វើឡើងដើម្បីទទួលបានសេចក្ដីលំអិតអំពីរចនាសម្ព័ន្ធការងារនៅក្នុង តំបន់ដូចជា ទំហំ និងលក្ខណៈនានារបស់កំលាំងពលកម្ម របស់អ្នកគ្មានការងារធ្វើក៏ដូចជាលទ្ធភាពនិងប្រភេទការងារផងដែរ។ ទស្សនវិស័យពិសេសៗដែល តែងតែប្រើក្នុងការប្រមូល ពតិមានរួមមាន :

- ទំហំ និង អាយុរបស់ពលករ
- អាត្រាការចូលរួមរបស់ពលករ សំរាប់ស្ត្រី និង បុរស
- មុខងារ និង ឧស្សាហកម្មរបស់ពលករ
- ចំនួន និង ភាគរយរបស់អ្នកអត់ការងារធ្វើ
- លក្ខណៈនានារបស់អ្នកអត់ការងារធ្វើ : អាយុ ភេទ ជនជាតិ និងរយៈពេលអត់ការងារធ្វើ
- ចំនួនប្រភេទ និង ទីតាំងរបស់ការងារដែលនៅទំនេរ
- ការធ្វើដំណើរទៅធ្វើការងារ



Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

គោលការណ៍និងដំណើរការទូទៅ

**៥- ហេដ្ឋារចនាសម្ព័ន្ធសង្គម :**

តើឥទ្ធិពលរបស់ស្ថាប័នសង្គមការសិក្សាអប់រំសុខាភិបាលការកំសាន្តវប្បធម៌ ឬនយោបាយ ទៅលើការរស់នៅរបស់សហគមន៍ នៅក្នុងតំបន់មានអ្វីខ្លះ ?ជំហ៊ានដ៏សំខាន់នៅក្នុងការកសាងកំណត់ត្រាលំអិតអំពីតំបន់គឺដើម្បីកំណត់នូវគ្រប់ស្ថាប័ន និង សេវាកម្ម និង បរិក្ខា ដែលផ្តល់ សំរាប់សង្គមកិច្ចរបស់ប្រជាជនដែលកំពុងរស់នៅក្នុងតំបន់ ។តាមរយៈដំណើរការនេះវាអាចសំរេច ថាតើសមត្ថភាពដែលមានលើសការខ្វះខាតឬចន្លោះប្រហោងដែលកើតមាននៅក្នុងការចែកចាយសេវាកម្ម ។ជាជំហ៊ានដំបូង ការចុះបញ្ជី សារពើភណ្ឌត្រូវតែបំពេញនូវ :

- **សហគមន៍ និង ស្ថាប័នសាសនា :** ស្ថាប័នសាសនានានា ក្រុមកីឡាផ្សេងៗ ក្លឹបសេវាកម្មនានា ក្រុមវប្បធម៌នានាក្រុមយុវជន និង ស្ថាប័នសហគមន៍ដ៏ទៃទៀត ។
- **សេវាកម្មជំនាញនានា :** ផ្នែកសុខាភិបាល សុខភាព ទន្តពេទ្យ ពេទ្យសត្វ មេធាវី នីតិវិធី រថយន្តពន្លត់អគ្គីភ័យ ប្រៃសណីយ៍ នគរបាល បណ្ណាល័យ ។ល។
- **សេវាកម្មនានារបស់រដ្ឋាភិបាល ( រដ្ឋ និង មូលដ្ឋាន ) :** សុខភាពសេវាកម្មសហគមន៍នានា កសិកម្ម ។ល។
- **ការសិក្សាអប់រំ :**មត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា ការសិក្សាអប់រំរបស់សហគមន៍ ។ល។
- **សេវាកម្មនានាផ្នែកសុខភាព និង សង្គមកិច្ច :** សុខភាពកុមារ សាលារៀន និង សុខភាពរបស់សហគមន៍ ផ្ទះសំរាក និងមជ្ឈមណ្ឌលបំប៉នសុខភាពរបស់សហគមន៍ ។ល។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

**គោលការណ៍និងដំណើរការផ្ទុះនៅ**

## ៦- ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត :

ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត រួមមានផ្លូវ ការផ្គត់ផ្គង់ទឹក អគ្គសនី ទូរគមនាគមន៍ វាលយន្តហោះ កំពុងផែ។ តើសមាសធាតុរូបវ័ន្តណាខ្លះមានសារៈសំខាន់នៅក្នុងតំបន់? ការស៊ើបអង្កេតអំពីហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត នៅក្នុងតំបន់ ត្រូវមាន :

- ការប្រើប្រាស់និងការកាន់កាប់ដីធ្លី : ប្រព័ន្ធនៃការរៀបចំផែនការទីប្រជុំជន និងទីក្រុងយុទ្ធសាស្ត្រជនបទ ការគ្រប់គ្រងអភិវឌ្ឍន៍ ការប្រើប្រាស់និង កាន់កាប់ដីធ្លីនៃតំបន់ធំៗ ។ល។
- ការអភិវឌ្ឍន៍លំនៅដ្ឋានៈ ចំនួនប្រភេទតំលៃ និងកម្មសិទ្ធិរបស់លំនៅដ្ឋានដែលបានកាន់កាប់ ឬមិនទាន់បានកាន់ កាប់ ដីធ្លីនៅទំនេរ ការកសាង ឬ តំឡើង និងវាយកំទេចចោលផ្ទះសំបែង ។ល។
- ការអភិវឌ្ឍន៍ផ្នែកហិរញ្ញវត្ថុ : ចំនួនប្រភេទ និងកម្មសិទ្ធិរបស់បរិវេនហិរញ្ញវត្ថុដែលមាន ឬ គ្មានការកាន់កាប់ ដីហិរញ្ញវត្ថុទំនេរ តំលៃរបស់ដី ។ល។
- ការអភិវឌ្ឍន៍ផ្នែកឧស្សាហកម្ម : ចំនួនប្រភេទ និង កម្មសិទ្ធិរបស់ឧស្សាហកម្មនានា ដីដែលបាន និងមិនបាន ធ្វើអាជីវកម្មឧស្សាហកម្ម ។ល។
- ដីបំរុង : ទំហំប្រភេទ និងទីតាំងរបស់ដីបំរុងដែលមាន ឬ គ្មានការអភិវឌ្ឍន៍ ។ល។
- អាគាររបស់សហគមន៍ : ទំហំប្រភេទកម្មសិទ្ធិ និង បទដ្ឋានរបស់អាគារ របស់សហគមន៍ដែលមាន ឬ គ្មានការកាន់កាប់ ។ល។
- ការផ្គត់ផ្គង់ទឹក : ប្រភេទ បរិវេណ និងគុណភាពរបស់ការផ្គត់ផ្គង់បច្ចុប្បន្ន និងនៅពេលអនាគត ។ល។
- ប្រពន្ធ័លូទឹក :បរិវេណប្រពន្ធ័ដែលកំពុងប្រើប្រាស់បច្ចុប្បន្ន ។ល។
- ការផ្គត់ផ្គង់អគ្គីសនី និងឧស្ម័នៈ លទ្ធភាពការប្រើប្រាស់បរិវេ ណនៃការ ផ្តល់សេវាកម្មយុទ្ធសាស្ត្រអភិរក្ស ថាមពល ។ល។
- ការដឹកជញ្ជូន : ផ្លូវ ផ្លូវដែក ផ្លូវអាកាស តំបន់ឆ្នេរ និងបរិក្ខានានា ទីកន្លែងស្តុកទុក ។ល។ការវិភាគអំពីការប្រើប្រាស់បច្ចុប្បន្ន លទ្ធភាពគុណភាពនិងតំលៃ របស់ហេដ្ឋា រចនាសម្ព័ន្ធផ្នែករូបវ័ន្តផ្តល់នូវការចង្អុលបង្ហាញ នូវភាពគ្រប់គ្រាន់និងភាពត្រឹមត្រូវរបស់បរិក្ខានានា ដើម្បីឆ្លើយតបបាន នឹងតំរូវការបច្ចុប្បន្ននិងទៅអនាគតក្នុងតំបន់ ។

គោលការណ៍និងដំណើរការទូទៅ

### ៧- ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច :

តើតំបន់បង្កើតប្រាក់ចំណូលរបស់ខ្លួនយ៉ាងដូចម្តេច ? តើតំបន់នោះពង្រីកភាពរីកចំរើនរបស់ខ្លួនទៅទីណា ? តើភាពសំបូរ ផលនោះត្រូវបានចែកចាយដូចម្តេច ?ផ្នែកនេះនៃការកំណត់ត្រាលំអិតរបស់សហគមន៏ផ្តល់នូវការពិពណ៌នា និងការវិភាគអំពីសេដ្ឋកិច្ចមូលដ្ឋាន វាគួរតែផ្តល់នូវការចង្អុលបង្ហាញអំពីភាពសំបូរបែបនិង លទ្ធភាពបច្ចុប្បន្ននៃសេដ្ឋកិច្ចមូលដ្ឋានឱកាសនានាសំរាប់ការបង្កើត មុខជំនួញថ្មីៗ និងការពង្រីកមុខជំនួញដែលមានស្រាប់អំពីបញ្ហា និងឧបស័គ្គនានាដល់សេដ្ឋកិច្ចមូលដ្ឋានដែលអាចបក ស្រាយបានដោយសហគមន៏ មូលដ្ឋាន និងការលើកឡើងនូវដំណោះស្រាយនៅមូលដ្ឋានដើម្បីដោះស្រាយបញ្ហានានា ។ ពតិមានដែលបានស្វែងរកជាធម្មតា មាន :

- ចំនួននិងប្រភេទមុខជំនួញ និងឧស្សាហកម្មដែល បានប៉ាន់ប្រមាណទៅលើផលិតផលឧស្សាហកម្ម ដែលត្រូវ នាំចេញទៅឬនាំចូលពីតំបន់ជិតខាងនានា ។
- ក្របខ័ណ្ឌច្បាប់
- កម្មសិទ្ធិ ចំនួនអ្នកធ្វើការដោយខ្លួនឯង ឬ ចំនួននិយោជក
- ស្ថេរភាពមុខជំនួញ រូបភាពទៅលើចំនួនប្រាក់ទទួលបានសរុបសំរាប់មុខជនួញលក់រាយ និងមុខជំនួញផលិត ។
- ការងារ មុខរបរ ចំនួនសរុបនៃកំលាំងពលកម្ម កំរិតប្រាក់ខែនៅក្នុងវិស័យការលក់រាយ និងការផលិត ការចូលរួមរបស់កំលាំងពលកម្មការងារមិនពេញម៉ោងនិងពេញម៉ោងធ្វើការ និងរូបភាព បង្ហាញពីអាត្រាអត់ការងារ ធ្វើដែលមាន :
- ជំនាញរបស់កំលាំងពលកម្មឧទាហរណ៏កំរិតនិងប្រភេទនៃការហ្វឹកហ្វឺន និងចំណេះដឹងដែលទទួលបាន ។
- ប្រភពដើមរបស់សំភារៈនានា ។
- ពង្រីកទីតាំងផ្តល់សេវាកម្ម
- កំណត់និងឧបស័គ្គធំៗ ដែលប៉ះពាល់ដល់មុខជំនួញក្នុងតំបន់
- សេវាកម្ម និងផលិតផលដែលបានចែកចាយដោយមុខជំនួញក្នុងតំបន់
- កំណត់ដំណោះស្រាយដែលអាចធ្វើទៅបានសំរាប់បញ្ហានានា

## References and Sources Used



Jenssen, B.;(ed), **Planning as a Dialogue,** District Development Planning and Management in Developing Countries, SPRING Research Series Nr. 2, Dortmund, 1992

Jenssen, B.; **Towards a Quantification of Agglomeration Disadvantages in Metroploitan Areas of Developing Countries**, University of Dortmund, IRPUD, 1984

Rondinelli, Dennis, A.: **Applied Methods of Regional Planning: The Urban Functions in Rural Development Approach**, Clark University: Rural Marketing Centers Working Group (USAID), 1983a

Thimm, Hr.R., Green, D.A.G., Leupolt, M. (Eds); P**lannning and Operating Rural Centres in Developing Countries,** Studien zur Ländlichen Entwicklung. No. 18, 1986

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)